**Declassified to Public**
**12 June 2020**



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**Kingdom of Cambodia**
**Nation Religion King**

**Royaume du Cambodge**
**Nation Religion Roi**

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

---

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 27-Sep-2016, 09:21
CMS/CFO: Ly Bunloung

**សំណុំរឿងលេខ៖ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក -ក.ស.ច.ស**

ចំពោះមុខ ៖ **សហចៅក្រមស៊ើបអង្កេត**

កាលបរិច្ឆេទ ៖ **ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៦**

ភាសា ៖ **អង់គ្លេស [ភាសាដើម]**

ចំណាត់ថ្នាក់ឯកសារ ៖ **សម្ងាត់**

---

# ដីកាសម្រេចរួមលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បញ្ចូលឯកសារនៃសំណុំរឿង ០០៤ ទៅក្នុងសំណុំរឿង ០០២

**(D193/92 និង D193/93)**

---

**ផ្ញើជូន៖**

**អង្គជំនុំជម្រះសាលាដំបូង**

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**មេធាវីការពារក្តី អោ អាន**

**មេធាវីតំណាង**
**ដើមបណ្តឹងរដ្ឋប្បវេណី៖**
ជេត វណ្ណលី
ហុង គឹមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន សុវ៉ន

Ferdinand DJAMMEN-NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Emmanuel JACOMY
Martine JACQUIN
Christine MARTINEAU
Barnabe NEKUI
Lyma NGUYEN

មុំ លុច
Richard ROGERS
Göran SLUITER

**មេធាវីការពារក្តី យឹម និត្យ**

SO Mosseney
Suzana TOMANOVIĆ

ទី ស្រ៊ីនណា
វ៉ែន ពៅ

Linda BEHNKE
Laure DESFORGES
Herve DIAKIESE

Beini YE



Extraordinary Chambers in the Courts of Cambodia, National Road 4, Chaom Chao, Porsenchey, Phnom Penh
PO Box 71, Phnom Penh, Tel: +855(0)23 218914, Fax: +855(0) 23 218941.

Original EN: 01321857-01321861

## I. ប្រវត្តិនីតិវិធី និង សារណា

1. ករណីខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត (“ស.ច.ស”) នៅក្នុងសំណុំរឿងនេះ បានចុះបញ្ជី នៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣, ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១៣ និង ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៤។

2. នៅថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១៤ សហចៅក្រមស៊ើបអង្កេតមុន បានចេញ *ដីកាសម្រេចលើសំណើបន្ទាន់របស់សហព្រះរាជអាជ្ញា សុំដាក់បង្ហាញចម្លើយដែលពាក់ព័ន្ធនឹងសំណុំរឿង ០០៤ ចូលទៅក្នុងវគ្គទី ១ នៃសវនាការក្នុងសំណុំរឿង ០០២/០២* [1]។ យើងបញ្ចូលផ្នែកនៃកថាខណ្ឌ ១ ដល់ ៧ នៃដីកាសម្រេចនោះ ដើម្បីជាសេចក្តីយោង។

3. នៅថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០១៥ យើងបានចេញ *អនុស្សរណៈពី ក.ស.ច.ស ទៅអង្គជំនុំជម្រះសាលាដំបូង និង អង្គជំនុំជម្រះតុលាការកំពូល ពាក់ព័ន្ធនឹង "ការដាក់បង្ហាញឯកសារពីសំណុំរឿង ០០៣ និង ០០៤ ទៅក្នុងក្នុងសំណុំរឿង ០០២"* ដែលក្នុងនោះយើងបានដាក់កំហិត និង កំណត់បែបបទមួយចំនួនសម្រាប់ការដាក់បង្ហាញឯកសារ[2]។

4. នៅថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១៦ សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់សំណើសុំអនុញ្ញាតដាក់បង្ហាញឯកសារយោងចំនួន ១០ ក្នុងសំណុំរឿង ០០៤ ទៅក្នុងសំណុំរឿង ០០២ (“D193/92)[3]។ នៅថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៦ មេធាវីការពារក្តីរបស់ អោ អាន និង យឹម ទិត្យ បានផ្ញើសារអេឡិចត្រូនិកមួយ ដោយលើកឡើងថា ពួកគាត់គ្មានបំណងឆ្លើយតបទៅនឹងសំណើ D193/92[4] នេះទេ។

---

[1] សំណុំរឿងលេខ 004-D193/4, *ដីកាសម្រេចលើសំណើបន្ទាន់របស់សហព្រះរាជអាជ្ញា សុំដាក់បង្ហាញចម្លើយដែលពាក់ព័ន្ធនឹងសំណុំរឿង ០០៤ ចូលទៅក្នុងវគ្គទី ១ នៃសវនាការក្នុងសំណុំរឿង ០០២/០២* ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១៤។

[2] សំណុំរឿងលេខ 004-D273, *អនុស្សរណៈពី ក.ស.ច.ស ទៅអង្គជំនុំជម្រះសាលាដំបូង និង អង្គជំនុំជម្រះតុលាការកំពូល ពាក់ព័ន្ធ“ការដាក់បង្ហាញឯកសារពីសំណុំរឿង ០០៣ និង ០០៤ ទៅក្នុងសំណុំរឿង ០០២”*, ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០១៥។

[3] សំណុំរឿងលេខ 004-D193/92, *សំណើបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញឯកសារនៃសំណុំរឿង ទៅក្នុងសំណុំរឿង ០០២* ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១៦។

[4] សារអេឡិចត្រូនិកពីសហព្រះរាជអាជ្ញាអន្តរជាតិ បញ្ជូនបន្តសេចក្តីបញ្ជាក់របស់មេធាវីការពារក្តី, ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៦។



Extraordinary Chambers in the Courts of Cambodia, National Road 4, Chaom Chao, Porsenchey, Phnom Penh
PO Box 71, Phnom Penh, Tel: +855(0)23 218914, Fax: +855(0) 23 218941.

Original EN: 01321857-01321861

5. នៅថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៦ សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់សំណើសុំអនុញ្ញាតដាក់បង្ហាញឯកសារយោងចំនួន ០២ ទៅក្នុងសំណុំរឿង ០០៤ ("D193/93)[5]។ ដោយសារភាពបន្ទាន់នៃសំណើនោះ សារអេឡិចត្រូនិចដែលចុះថ្ងៃទី ១៨-១៩ ខែ សីហា ឆ្នាំ ២០១៦ ពីមេធាវីការពារក្តីរបស់ អោ អាន និង អ៊ឹម ចែម ដែលបញ្ជាក់បំណងមិនចង់ឆ្លើយតប ត្រូវបានភ្ជាប់មកជាមួយសំណើ[6]។ នៅថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១៦ សហព្រះរាជអាជ្ញាអន្តរជាតិ បានបញ្ជូនបន្តសារអេឡិចត្រូនិច របស់មេធាវីការពារក្តីរបស់ យឹម ទិត្យ ដែលបញ្ជាក់អំពីបំណងមិនចង់ឆ្លើយតប[7]នេះ។ នៅថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១៦ សហព្រះរាជអាជ្ញាអន្តរជាតិ បានជូនដំណឹងសហចៅក្រមស៊ើបអង្កេតអន្តរជាតិ តាមរយៈសារអេឡិចត្រូនិកផងដែរ ថាខ្លួនដកសំណើមួយទៅវិញ ក្នុងចំណោមឯកសារដែលស្នើសុំចំនួនពីរ[8]។ សារអេឡិចត្រូនិកឆ្លើយឆ្លងគ្នានេះ មាននៅក្នុងឧបសម្ព័ន្ធ ខ នៅក្នុងដីកាសម្រេចនេះ។

## II. សារណា

6. នៅក្នុងសំណើ D193/92 សហព្រះរាជអាជ្ញាអន្តរជាតិ ស្នើសុំដាក់បង្ហាញកំណត់ហេតុស្តាប់ចម្លើយសាក្សីចំនួន ០៧ របាយការណ៍ស្តីពីកិច្ចស៊ើបសួរចំនួន ០២ និង ផែនទីមួយដែលភ្ជាប់ទៅនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សីដែលធ្លាប់បានដាក់បង្ហាញពីមុន[9]។ សហព្រះរាជអាជ្ញាអន្តរជាតិ លើកឡើងថា ភាគច្រើននៃឯកសារទាំងនេះ មានផ្ទុកឯកសារដែលអាចដោះបន្ទុក និង ឯកសារមួយចំនួនត្រូវបានស្នើសុំឱ្យទទួលយកជាភ័ស្តុតាងនៅក្នុងសវនាការសំណុំរឿង ០០២/០២[10]។

7. នៅក្នុងសំណើ D193/93 សហព្រះរាជអាជ្ញាអន្តរជាតិ ស្នើសុំដាក់បង្ហាញពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ០១ និង កំណត់ហេតុស្តាប់ចម្លើយមួយរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា[11]។ សហព្រះរាជអាជ្ញាអន្តរជាតិ បានដកសំណើមួយទៅវិញ ពាក់ព័ន្ធនឹងកំណត់ហេតុស្តាប់ចម្លើយរបស់ម

---

[5] សំណុំរឿងលេខ 004-D193/93, *សំណើបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញឯកសារនៃសំណុំរឿង ទៅក្នុងសំណុំរឿង ០០២* ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៦។

[6] D193/93 កថាខណ្ឌ ៤ និង ឧបសម្ព័ន្ធ ក និង ខ។

[7] ឧបសម្ព័ន្ធ ខ សារអេឡិចត្រូនិកពីសហព្រះរាជអាជ្ញាអន្តរជាតិ បញ្ជូនបន្តសេចក្តីបញ្ជាក់របស់មេធាវីការពារក្តី យឹម ទិត្យ, ចុះថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១៦។

[8] ឧបសម្ព័ន្ធ ខ សារអេឡិចត្រូនិកពីសហព្រះរាជអាជ្ញាអន្តរជាតិ ស្នើសុំដកឯកសារមួយ, ចុះថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១៦។

[9] D193/92 ឧបសម្ព័ន្ធ ក។

[10] D193/92 ទំព័រទី ១ និង ឧបសម្ព័ន្ធ ក។

[11] D193/93 ឧបសម្ព័ន្ធ ក។

ជ្ឈមណ្ឌលឯកសារកម្ពុជា ដោយសារកំហុសផ្នែកអត្តសញ្ញាណ។ សំណើសុំដកនេះ ត្រូវបានយល់ព្រមតាមសារអេឡិចត្រូនិក ដោយសារតែភាពបន្ទាន់នៃសំណើ។ សហព្រះរាជអាជ្ញាអន្តរជាតិ ត្រូវបានបង្គាប់ឱ្យដាក់សំណើសុំដកសំណើទៅវិញ នៅពេលអនាគត តាមតម្រង់ដូចការដាក់សំណើទូទៅមួយដើម្បីរក្សាកំណត់ហេតុពេញលេញ និង ត្រឹមត្រូវសម្រាប់ការដាក់បង្ហាញ។ ចំពោះឯកសារនៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលនៅសេសសល់ សហព្រះរាជអាជ្ញាអន្តរជាតិ លើកឡើងបន្ថែមថា ចម្លើយពីមុនរបស់បុគ្គលទាំងនោះ មាននៅក្នុងសំណុំរឿង ០០២ រួចជាស្រេចហើយ មានខ្លះអាចរកបាននៅក្នុងមជ្ឈដ្ឋានសាធារណៈ។ ដូច្នេះ ការដាក់បង្ហាញឯកសារនេះ មិនតម្រូវឱ្យមានវិធានការការពារធម្មតា ដូចមានកំណត់ក្នុងប្រភេទ ក នោះឡើយ[12]។

8. នៅថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ អង្គជំនុំជម្រះសាលាដំបូង បានស្នើសុំការបញ្ជាក់ពាក់ព័ន្ធនឹងតម្រូវការនៃវិធានការការពារ ចំពោះដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ យឿន ដែលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់គាត់ ត្រូវបានដាក់បង្ហាញតាមរយៈដីកាសម្រេច D193/61 នៅក្នុងប្រភេទ ក ដោយសារតែសារណាផ្ទាល់មាត់របស់សហព្រះរាជអាជ្ញា នៅក្នុងកិច្ចដំណើរការនីតិវិធី ដែលឯកសារនេះត្រូវបានដាក់បង្ហាញ អាចរកបាននៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗ នៅក្នុងសំណុំរឿង ០០២[13]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានកំណត់ភាពខុសគ្នានៃលក្ខខណ្ឌពីពេលមុន ដោយផ្អែកលើព័ត៌មានថ្មី ដែលទទួលបានតាមរយៈសារអេឡិចត្រូនិក ដែលផ្ញើទៅកាន់អង្គជំនុំជម្រះសាលាដំបូង ហើយនឹងធ្វើការបញ្ជាក់ដូចគ្នានៅក្នុងដីកាសម្រេចនេះ[14]។ សារអេឡិចត្រូនិកឆ្លើយឆ្លងគ្នានេះ អាចរកបាននៅក្នុងឧបសម្ព័ន្ធ គ នៅក្នុងដីកាសម្រេចនេះ។

## III. ពិភាក្សា

9. ចំពោះសំណើ D193/92 ឯកសារដែលបានស្នើសុំទាំង ១០ នោះ មានភាពពាក់ព័ន្ធជាបឋមទៅនឹងសំណុំរឿង ០០២ និង ការដាក់បង្ហាញវា នឹងមិនធ្វើឱ្យប៉ះពាល់ដល់សុចរិតភាព និង ភាពសម្ងាត់នៃការស៊ើបអង្កេតដែលកំពុងប្រព្រឹត្តទៅនេះទេ។ ដោយសារសក្ខីកម្មរបស់ពួកគាត់ ពាក់ព័ន្ធនឹងការស៊ើប

---

[12] D193/93 ឧបសម្ព័ន្ធ ក។

[13] ឧបសម្ព័ន្ធ គ សារអេឡិចត្រូនិចពីអង្គជំនុំជម្រះសាលាដំបូង ទៅកាន់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ, ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦។

[14] ឧបសម្ព័ន្ធ គ សារអេឡិចត្រូនិចឆ្លើយតបពីសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ទៅអង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦។



Extraordinary Chambers in the Courts of Cambodia, National Road 4, Chaom Chao, Porsenchey, Phnom Penh
PO Box 71, Phnom Penh, Tel: +855(0)23 218914, Fax: +855(0) 23 218941.

Original EN: 01321857-01321861

អង្កេតដែលកំពុងប្រព្រឹត្តទៅ ក្នុងសំណុំរឿង ០០៤ សាក្សីដែលពាក់ព័ន្ធទាំងអស់នោះ នឹងត្រូវចាត់ក្នុងប្រភេទ ក។

10. ចំពោះសំណើ D193/93 ឯកសារដែលបានស្នើសុំមួយនោះ មានភាពពាក់ព័ន្ធជាបឋមទៅនឹងសំណុំរឿង ០០២ និង ការដាក់បង្ហាញវា នឹងមិនធ្វើឲ្យប៉ះពាល់ដល់សុចរិតភាព និង ភាពសម្ងាត់នៃការស៊ើបអង្កេតដែលកំពុងប្រព្រឹត្តទៅនេះទេ។ ដោយសារសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ពាក់ព័ន្ធនឹងការស៊ើបអង្កេតដែលកំពុងប្រព្រឹត្តទៅ ក្នុងសំណុំរឿង ០០៤ ពួកគាត់នឹងត្រូវចាត់ក្នុងប្រភេទ ក ប៉ុន្តែ មិនតម្រូវឲ្យមានលក្ខខណ្ឌកំហិតក្នុងការការពារអត្តសញ្ញាណរបស់ពួកគាត់ឡើយ ដោយសារធាតុផ្សំសំខាន់ៗនៃភ័ស្តុតាងរបស់ពួកគាត់ អាចរកបាននៅមជ្ឈដ្ឋានសាធារណៈរួចហើយ។

11. ដីកាសម្រេចនេះដាក់ជាភាសាអង់គ្លេស ដោយឯកសារបកប្រែជាភាសាខ្មែរ នឹងដាក់តាមក្រោយដោយសារតែភាពបន្ទាន់នៃបញ្ហានេះ និង ធនធានមានកម្រិតផ្នែកបកប្រែភាសា។

**តាមសម្អាងហេតុខាងលើ យើង៖**

12. **អនុញ្ញាត** ឲ្យដាក់បង្ហាញឯកសារទាំងអស់ ដែលមានក្នុងឧបសម្ព័ន្ធ ក នៃដីកាសម្រេចនេះ នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និង ភាគីក្នុងសំណុំរឿង ០០២/០២។ ដោយសារតែភាពសម្ងាត់ និងរសើបនៃការស៊ើបអង្កេតដែលកំពុងប្រព្រឹត្តទៅក្នុងសំណុំរឿង ០០៤ ឯកសារទាំងនេះអនុញ្ញាតឲ្យដាក់បង្ហាញតាមបែបបទ និង ការកំហិតដូចតទៅនេះ៖

(ក) រាល់ឯកសារទាំងអស់ដែលផ្តល់ជូនពីសំណុំរឿង ០០៤ ត្រូវចាត់ទុកថាជាឯកសារសម្ងាត់។

ខ) ក្នុងករណីដែលឯកសារដែលបានផ្តល់ជូនតាមរយៈដីកាសម្រេចនេះ ត្រូវបានទទួលយកជាភស្តុតាងនៅក្នុងសំណុំរឿង ០០២ នោះ ឯកសារនេះត្រូវចាត់ទុកថាជាឯកសារសម្ងាត់។

គ) គ្មានឯកសារណាដែលបានផ្តល់ជូនតាមរយៈដីកាសម្រេចនេះ ត្រូវផ្សព្វផ្សាយឲ្យហួសពីអ្វីដែលបានកំណត់យ៉ាងច្បាស់នៅក្នុងដីកាសម្រេចនេះឡើយ។

ឃ) ក្នុងករណីដែលសាក្សី ឬ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលឯកសាររបស់គាត់ ត្រូវបានអនុញ្ញាតឲ្យដាក់បង្ហាញក្នុងឧបសម្ព័ន្ធ ក ត្រូវបានកោះហៅឲ្យមកផ្តល់សក្ខីកម្ម ពួកគាត់អាចផ្តល់សក្ខីកម្មបាននៅក្នុងសវនាការសាធារណៈ ដរាបណាឈ្មោះ និង អត្តសញ្ញាណរបស់គាត់រក្សាការសម្ងាត់។



Extraordinary Chambers in the Courts of Cambodia, National Road 4, Chaom Chao, Porsenchey, Phnom Penh
PO Box 71, Phnom Penh, Tel: +855(0)23 218914, Fax: +855(0) 23 218941.

(ង)គ្មានឯកសារណា ដែលបានផ្តល់ជូនដូចមានក្នុងឧបសម្ព័ន្ធ ក ត្រូវផ្សព្វផ្សាយដល់សាធារណជន ក្នុងទម្រង់ណាមួយ ឬតាមរយៈរូបភាពណាមួយនៃប្រព័ន្ធផ្សព្វផ្សាយអ្វីក៏ដោយ ដែលហួសពីភស្តុតាងដែលបានបង្ហាញនៅក្នុងសវនាការសាធារណៈ។

(ច)ភាគី មេធាវី ឬ បុគ្គលផ្សេងទៀតណាក៏ដោយដែលអាន ដកស្រង់ ឬក៏ប្រើប្រាស់ឯកសារដែលបានបង្ហាញក្នុង ត្រូវតែបង្ហាញអត្តសញ្ញាណសាក្សី ឬ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី តែតាមរយៈរហស្សនាមដែលគេដាក់ឲ្យគាត់តែប៉ុណ្ណោះសម្រាប់សំណុំរឿង ០០២/០២ ហើយប្រើប្រាស់ការពិពណ៌នានាដែលផ្សព្វផ្សាយឲ្យបានសមហេតុផល ដើម្បីចៀសវាងបង្ហាញអត្តសញ្ញាណសាក្សីតាមរយៈព័ត៌មានផ្សេងទៀត។

ឆ) កំណត់ហេតុនៃការស្តាប់ចម្លើយ ដែលអនុញ្ញាតឲ្យដាក់បង្ហាញនេះត្រូវតែផ្តល់ជូនទៅក្រុមមេធាវីការពារក្តីរបស់ជនជាប់ចោទទាំងពីរ មេធាវីប្រចាំការរបស់ ខៀវ សំផន (“មេធាវីប្រចាំការ”) និងសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីតាមរយៈសំណៅអេឡិចត្រូនិក។

ជ) មេធាវីការពារក្តី មេធាវីប្រចាំការ និងសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបង្ហាញឯកសារដែលបានផ្តល់ជូនតាមរយៈដីកាសម្រេចនេះ ឲ្យទៅតែសមាជិកណានៅក្នុងក្រុមការងាររបស់ខ្លួនដែលទទួលបានការងារជាផ្លូវការតាមវិធានផ្ទៃក្នុង ២២(៥)និង១២*ស្ទួនពីរ*(៤) ព្រមទាំង កម្មសិក្សាការីដែលទទួលបានការចាត់តាំងផ្លូវការតែប៉ុណ្ណោះ។

ឈ)មេធាវីការពារក្តី មេធាវីប្រចាំការ និងសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី មិនត្រូវបានអនុញ្ញាតឲ្យបោះពុម្ព ផលិតឡើងវិញ ថតចម្លង ស្កេន ឬក៏ថតចម្លងសំណៅ ឯកសារដើមក្រៅពីគោលបំណងប្រើប្រាស់ផ្ទៃក្នុងដែលបានផ្តល់ជូនខ្លួនពីសមាជិកក្រុមការងាររបស់ខ្លួន ដែលត្រូវបានណែនាំ ឬអនុញ្ញាតឲ្យចូលពិនិត្យមើលឯកសារសម្ងាត់។

ញ) មេធាវីការពារក្តី មេធាវីប្រចាំការ និងសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី ត្រូវរក្សាទុកកំណត់ហេតុជាយលក្ខណ៍អក្សរនៃសំណៅដែលខ្លួនបោះពុម្ព ផលិតឡើង វិញ ថតចម្លង ស្កេន ឬក៏ថតចម្លងសម្រាប់ការប្រើប្រាស់ផ្ទៃក្នុង គឺត្រូវរក្សាទុកក្នុងរបៀបមួយដែលអាចត្រួតពិនិត្យឡើង វិញបាន និង

ដ) ប្រសិនបើសមាជិកណាម្នាក់នៃភាគីនានា ឬ អង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង ០០២/០២ ដឹង អំពីសំណៅគ្មានការអនុញ្ញាតឲ្យដាក់បង្ហាញណាមួយ ក្នុងចំណោមកំណត់ហេតុនៃការស្តាប់ចម្លើយដែលបានអនុញ្ញាតឲ្យដាក់បង្ហាញនោះ គាត់ត្រូវចាត់គ្រប់វិធានការភ្លាមៗ ដើម្បីរក្សា សុវត្ថិភាពសំណៅនោះ និងប្រគល់សំណៅនោះជូន ស.ច.ស វិញ និង



Extraordinary Chambers in the Courts of Cambodia, National Road 4, Chaom Chao, Porsenchey, Phnom Penh
PO Box 71, Phnom Penh, Tel: +855(0)23 218914, Fax: +855(0) 23 218941.

Original EN: 01321857-01321861

ឋ) ប្រសិនបើសមាជិកណាម្នាក់នៃភាគីនានា ឬអង្គជំនុំជម្រះសាលាដំបូង នៅក្នុងសំណុំរឿង ០០២/០២ ដឹងអំពីការរំលោភបំពានលក្ខខណ្ឌ និងការដាក់កំហិតទាំងនេះ គាត់ត្រូវរាយការណ៍ការរំលោភបំពានបែបនេះជូន ស.ច.ស។

13. **លើកលែង** អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ព្រាម ឈុន និង អ៊ុំ យឿន ចេញពីកថាខណ្ឌ ១២(ឃ) និង (ច) ខាងលើ៖

14. **បញ្ជាក់**ថា សម្រាប់គោលបំណងនៃដីកាសម្រេចនេះ ពាក្យថា "សាធារណជន" គឺមានន័យរាប់បញ្ចូលទាំងជនគ្រប់រូប រដ្ឋាភិបាល អង្គការ ស្ថាប័ន កូនក្តី សមាគម និងក្រុមមនុស្សគ្រប់ប្រភេទទាំងអស់ ដែលមិនមែនជាចៅក្រមនៅអង្គជំនុំជម្រះតុលាការកំពូល បុគ្គលិកផ្នែកគ្រប់គ្រងតុលាការ សហព្រះរាជអាជ្ញា តំណាងរបស់សហព្រះរាជអាជ្ញា ជនជាប់ចោទ បុគ្គលិកណាដែលទទួលបាន ការងារជាផ្លូវការតាមវិធានផ្ទៃក្នុង ២២(៥) និង ១២*ស្ទួនពីរ*(៤) ហើយទទួលបានការអនុញ្ញាតពី មេធាវីការពារក្តី មេធាវីប្រចាំការ និង សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីឲ្យចូលពិនិត្យមើលឯកសារសម្ងាត់។ ពាក្យថា "សាធារណជន" ក៏រាប់បញ្ចូលដោយមិនកំណត់ផងដែរទាំងសមាជិក គ្រួសាររបស់ជនជាប់ចោទ មិត្តភក្តិ សហការី ជនសង្ស័យ មេធាវីការពារក្តី និង សមាជិក បុគ្គលិក របស់ខ្លួននៅក្នុងរឿងក្តី ឬកិច្ចដំណើរការនីតិវិធីផ្សេងទៀតនៅចំពោះមុខ អ.វ.ត.ក ព្រមទាំងប្រព័ន្ធផ្សព្វផ្សាយ និងអ្នកសារព័ត៌មាន។

15. **បញ្ជាក់** ថាលក្ខខណ្ឌ និង ការដាក់កំហិតខាងលើ ត្រូវនៅជាធរមានរហូតដល់ពេលដែល ស.ច.ស ចេញដីកាច្បាស់លាស់ណាមួយដែលផ្ទុយពីលក្ខខណ្ឌ និង ការដាក់កំហិតទាំងនោះ ឬ ក៏ការស៊ើបអង្កេតនៅក្នុងសំណុំរឿង ០០៤ ត្រូវបានចាត់ទុកថាបិទបញ្ចប់។

16. **ស្នើ** អង្គជំនុំជម្រះសាលាដំបូង ធានាថា ភាគីទាំងអស់គោរពតាមដីកាសម្រេចនេះ។

ភ្នំពេញ ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៦

**ចៅក្រម Michael Bohlander**

**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**

**International Co-Investigating Judge**
**Co-juge d'instruction international**



Extraordinary Chambers in the Courts of Cambodia, National Road 4, Chaom Chao, Porsenchey, Phnom Penh
PO Box 71, Phnom Penh, Tel: +855(0)23 218914, Fax: +855(0) 23 218941.

Original EN: 01321857-01321861